# សេចក្តីជូនដំណឹង
# ស្តីពីការបែងចែកភាគលាភប្រចាំឆ្នាំ២០២០ ជូនដល់ភាគហ៊ុនិកសាធារណៈ របស់ ធនាគារ អេស៊ីលីដា ភីអិលស៊ី

**ធនាគារ អេស៊ីលីដា ភីអិលស៊ី ("ធ.អ.ក")** សូមជម្រាបជូនភាគហ៊ុនិកដែលកាន់កាប់ភាគហ៊ុនរបស់ ធ.អ.ក មេត្តាទទួលជ្រាបថាៈ យោងតាមសេចក្តីសម្រេច នៃកិច្ចប្រជុំមហាសន្និបាតភាគហ៊ុនិកលើកទី២១ ដែលបានប្រព្រឹត្តទៅកាលពីថ្ងៃទី២២ ខែមេសា ឆ្នាំ២០២១, លិខិតលេខ ៧៨៤/២១ ន.ម.ក. ចុះថ្ងៃសុក្រ ១១រោច ខែពិសាខ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥ ត្រូវនឹងថ្ងៃទី៧ ខែឧសភា ឆ្នាំ២០២១ របស់និយ័តករមូលបត្រកម្ពុជា ស្តីពីការបែងចែកភាគលាភសម្រាប់ឆ្នាំ២០២០ និងលិខិតលេខ ធ៧-០២១-៨០២ ធ.ត ចុះថ្ងៃពុធ ១៥កើត ខែជេស្ឋ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥ ត្រូវនឹងថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០២១ របស់ធនាគារជាតិ នៃ កម្ពុជា ស្តីពី ករណីធនាគារ អេស៊ីលីដា ភីអិលស៊ី ស្នើសុំបែងចែកភាគលាភ សម្រាប់ប្រាក់ចំណេញឆ្នាំ២០២០ ធ.អ.ក សម្រេចបែងចែកភាគលាភសម្រាប់ប្រាក់ចំណេញឆ្នាំ២០២០សម្រាប់ភាគហ៊ុនិកសាធារណៈតែប៉ុណ្ណោះ ចំណែកភាគលាភជាសាច់ប្រាក់ដែលនៅសល់ចំនួន ៩២.០៦៧.០៦០,៩១ដុល្លារអាមេរិក ត្រូវរក្សាទុកក្នុងខ្ទង់ប្រាក់ចំណេញរក្សាទុក សម្រាប់ធ្វើការបែងចែកជូនភាគហ៊ុនិកជានីតិបុគ្គល ដែលមិនមែនជាភាគហ៊ុនិកសាធារណៈ បន្ទាប់ពីនិយ័តករអនុម័ត។

ធ.អ.ក បានសម្រេចបែងចែកភាគលាភប្រចាំឆ្នាំ២០២០ ជូនភាគហ៊ុនិកសាធារណៈ ដូចខាងក្រោមៈ

| | | |
|---|---|---|
| ១. | ប្រភេទភាគលាភដែលត្រូវបែងចែក | : **សាច់ប្រាក់** |
| ២. | រយៈពេលភាគលាភ | : **ប្រចាំឆ្នាំ** |
| ៣. | អនុបាតនៃការបែងចែកភាគលាភសរុប | : **៣០%** |
| ៤. | ភាគលាភដែលត្រូវបែងចែក | : **៤២៦.២៣១,២៦ ដុល្លារអាមេរិក** |
| ៥. | ភាគលាភក្នុងមួយឯកតាមូលបត្រកម្មសិទ្ធិ | : **៣៩៩,២៦៧ រៀល** យោងតាមអត្រាប្តូរប្រាក់ផ្លូវការរវាងរូបិយប័ណ្ណដុល្លារអាមេរិកជាមួយប្រាក់រៀល របស់ធនាគារជាតិ នៃ កម្ពុជា នៅថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០២១ (៤០៧០ x 0,០៩៨១) |
| ៦. | កាលបរិច្ឆេទប្រកាសបញ្ជីឈ្មោះភាគហ៊ុនិកសាធារណៈដែលត្រូវទទួលភាគលាភ | : **ថ្ងៃទី៣ ខែឧសភា ឆ្នាំ២០២១** |
| ៧. | កាលបរិច្ឆេទទូទាត់ភាគលាភ | : **ថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០២១** |

**បញ្ជាក់ៈ**

- ភាគហ៊ុនិកសាធារណៈ ដែលមានសិទ្ធិទទួលបានភាគលាភដូចកំណត់ខាងលើ គឺភាគហ៊ុនិកដែលមានឈ្មោះនៅក្នុងបញ្ជីឈ្មោះភាគហ៊ុនិក នៅ**ថ្ងៃទី៣ ខែឧសភា ឆ្នាំ២០២១**។

ចុះបញ្ជីក្រោមលេខ
Registration No. 00003077

អគារលេខ៦១ មហាវិថីព្រះមុនីវង្ស សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
#61, Preah Monivong Blvd., Sangkat Srah Chork, Khan Daun Penh, Phnom Penh, Kingdom of Cambodia.
ទូរស័ព្ទ Tel: +855 (0) 23 998 777 / 430 999, ទូរសារ Fax: +855 (0) 23 430 555, ប្រអប់សំបុត្រ P.O.Box: 1149
E-mail: acledabank@acledabank.com.kh, Website: www.acledabank.com.kh, SWIFT Code: ACLBKHPP

- ភាគហ៊ុនិកសាធារណៈដែលធ្វើការលក់មូលបត្រកម្មសិទ្ធិរបស់ខ្លួននៅ**ថ្ងៃទី២៩ ខែមេសា ឆ្នាំ២០២១** នៅតែមានសិទ្ធិទទួលបានភាគលាភដដែល។
- ភាគហ៊ុនិកសាធារណៈ ដែលធ្វើការទិញមូលបត្រកម្មសិទ្ធិនៅ**ថ្ងៃទី២៩ ខែមេសា ឆ្នាំ២០២១** នឹងមិនមានសិទ្ធិទទួលបានភាគលាភទេ។
- ការទូទាត់ភាគលាភនឹងចាប់ផ្តើមពី**ថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០២១ ដល់ថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០២១** នៅរៀងរាល់ថ្ងៃធ្វើការ។ ភាគហ៊ុនិកអាចធ្វើការតវ៉ាលើការទូទាត់ភាគលាភក្នុងរយៈពេល៧ថ្ងៃ (នៃថ្ងៃធ្វើការ) បន្ទាប់ពីថ្ងៃបិទបញ្ចប់ការទូទាត់ភាគលាភ។

សម្រាប់ព័ត៌មានបន្ថែម សូមទំនាក់ទំនងមកធនាគារ អេស៊ីលីដា ភីអិលស៊ី តាមរយៈអាសយដ្ឋាន និងលេខទូរស័ព្ទទំនាក់ទំនងដូចខាងក្រោម៖


- **អាសយដ្ឋាន:** អគារលេខ៦១ មហាវិថីព្រះមុនីវង្ស សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ
- **លោក លឹម អាន** ប្រធានផ្នែកប្រតិបត្តិការ RTP
  - ទូរស័ព្ទ: (៨៥៥) ១៥ ៦០០ ៧៤៣
  - អ៊ីម៉ែល: lim.an@acledabank.com.kh
- **លោក ហួត សុភី** អនុប្រធានផ្នែកប្រតិបត្តិការ RTP
  - ទូរស័ព្ទ: (៨៥៥) ១៥ ៩០០ ៥៣៨
  - អ៊ីម៉ែល: huot.sophy@acledabank.com.kh
- **លោកស្រី សំរិទ្ធ វណ្ណីបុប្ផារដ្ឋ** បុគ្គលិកផ្នែកប្រតិបត្តិការ RTP
  - ទូរស័ព្ទ: (៨៥៥) ៦១ ២៨៧ ៧៦៦
  - អ៊ីម៉ែល: op.rtp@acledabank.com.kh


ថ្ងៃអង្គារ ៦រោច ខែជេស្ឋ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥

រាជធានីភ្នំពេញ ថ្ងៃទី០១ ខែមិថុនា ឆ្នាំ២០២១

**ធនាគារ អេស៊ីលីដា ភីអិលស៊ី**